## នាងអេសធើរ២:៤-១៥

**រួចមក ឯនាងណាដែលសព្វព្រះទ័យដល់ព្រះករុណា នោះសូមទ្រង់តាំងឡើងឱ្យធ្វើជាអគ្គមហេសី ជំនួសព្រះនាងវ៉ាសធីនោះ ស្តេចទ្រង់សព្វព្រះទ័យនឹងសេចក្តីនោះ ហើយក៏ធ្វើតាមដូច្នោះ (នាងអេសធើរ២:៤)។**

ការសម្រេចថា តើនារីណាមួយត្រូវឡើងធ្វើជាអគ្គមហេសី គឺត្រូវព្រះករុណាជាអ្នកសម្រេចដោយអង្គទ្រង់។ គ្មានជនណាអាចសម្រេចជំនួសស្តេចអង្គនេះបានទេ។

**រីឯនៅស៊ូសាន ជាទីក្រុងហ្លួង មានសាសន៍យូដាម្នាក់ឈ្មោះម៉ាដេកាយ ជាកូនយ៉ាអ៊ារ ដែលជាកូនស៊ីម៉ាយៗ ជាកូនគីស ក្នុងពូជបេនយ៉ាមីន (នាងអេសធើរ២:៥)។**

ចាប់តាំងពីពេលដែលយើងសិក្សាមេរៀនមកទល់ពេលនេះ សេចក្តីពិតដែលពិភាក្សាទាំងអម្បាលមាណមក គ្រាន់តែជាការតុបតែងឆាកប៉ុណ្ណោះ។ នៅក្នុងសេចក្តីផ្តើម ព្រះជាម្ចាស់បង្ហើបអោយយើងឃើញព្រឹត្តិការណ៍ដែលកើតឡើង នៅក្នុងរាជ្យរបស់ស្តេចដែលមិនស្គាល់ដល់ព្រះជាម្ចាស់។ ព្រឹត្តិការណ៍ទាំងនោះ ព្រះអង្គចង់អោយ

យើងឃើញ ព្រះទ័យបំណងរបស់ព្រះអង្គដែលទ្រង់គ្រប់គ្រង សូម្បីព្រឹត្តិការណ៍ដែលកើតឡើងក្នុងចំណោមពួកមនុស្សដែលមិនស្គាល់ព្រះអង្គក៏ដោយ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានអោយយើងឃើញការប្រលងរើសរកបវរកញ្ញា ដែលបើកជាផ្លូវនាំអោយនាងអេសធើរឡើងធ្វើជាអគ្គមហេសីរបស់ព្រះមហាក្សត្រ។ ដោយសារនាងជាអគ្គមហេសីពោលគឺជាបុគ្គលខ្ពស់បំផុតទីពីរនៅក្នុងនគរ នាងអាចជួយសង្គ្រោះដល់ជនជាតិរបស់នាងបាន។ បើនាងមិនបានឡើងមកទទួលនាទីជាអគ្គមហេសីទេ សាសន៍យូដាទាំងមូលនឹងត្រូវគេសម្លាប់ផ្តាច់ពូជនៅក្នុងពេលនោះហើយ។ ដូច្នេះ យើងឃើញព្រះហស្តរបស់ព្រះជាម្ចាស់ កំពុងធ្វើការជាមួយនឹងកិច្ចការនៅក្នុងព្រះរាជវាំងរបស់ក្សត្រដែលមិនស្គាល់ដល់ព្រះជាម្ចាស់។

មកទល់នឹងចំណុចនេះ សាច់រឿងដែលយើងបានសិក្សាកន្លងមក មិនមានតម្លៃខាងព្រលឹងវិញ្ញាណអ្វីបន្តិចបន្តួចសោះ។ ស្ថានភាពដែលកើតឡើងទាំងអម្បាលមាណ គឺសម្តែងពីប្រពៃណីទំនៀមទម្លាប់របស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់ ពោលគឺគេយកគ្រឿងស្រវឹង ការរួមដំណេកប្រុសស្រី ហើយនិងការអាក្រក់គ្រប់បែបយ៉ាងមកធ្វើជាត្រីមុខ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់ទ្រង់អាចប្រើស្ថានភាពទាំងនោះ ដើម្បីសម្រេចទិសដៅដ៏ល្អរបស់ទ្រង់ គឺព្រះអង្គចង់សម្តែងការឧបត្ថម្ភគាំទ្ររបស់ទ្រង់ចំពោះរាស្ត្ររបស់ព្រះអង្គ។ ព្រឹត្តិការណ៍ទាំងនោះកើតឡើងដើម្បីអោយទ្រង់អាចសម្តែងព្រះគុណរបស់ព្រះអង្គសង្គ្រោះ ដល់រាស្ត្ររបស់ទ្រង់គឺសាសន៍យូដា។

ទាក់ទងនឹងរឿងការប្រលងជ្រើសរើសបវរកញ្ញា អ្នកខ្លះនិយាយថា ដោយ

សារព្រះអង្គអនុញ្ញាតអោយនាងអេសធើរឈ្នះគេ ព្រះជាម្ចាស់ពិតជាយល់ព្រមកិច្ចការនោះជាប្រាកដ។ ក្នុងករណីនេះ កម្មវិធីប្រឡងជ្រើសរើសបវរកញ្ញានានាលើលោកយើងនេះ ប្រហែលជាសុទ្ធតែកើតមកពីព្រះជាម្ចាស់ហើយ។ ទេរឿងនេះឆ្ងាយពីការពិតណាស! ខ្ញុំជឿថា ព្រះអង្គមិនយល់ស្របចំពោះដំណើរនោះទេ។ លោកអ្នកបងប្អូនអើយ ពេលកូនរបស់ព្រះដើរឆ្ងាយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះអង្គអនុញ្ញាតអោយមានការជាច្រើន ពិសេសការដែលព្រះអម្ចាស់មិនសព្វព្រះទ័យកើតមានឡើងដល់កូនរបស់ទ្រង់។ ទោះបីស្ថានភាពទាំងនោះកើតមានឡើងដល់កូនរបស់ទ្រង់ក៏ដោយ ព្រះអង្គកំពុងតែមានឧត្តមភាពលើស្ថានភាពទាំងនោះដដែល។ ផែនការរបស់ទ្រង់មិនដែលប្តូរផ្លាស់ ដោយសារតែកូនរបស់ព្រះអង្គ ដើរខុសពីបំណងព្រះហឫទ័យរបស់ទ្រង់នោះទេ។ រឿងនេះ យើងឃើញសម្តែងជាឧទាហរណ៍ស្រាប់នៅក្នុងកណ្ឌព្រះគម្ពីរដ៏ស្តើងនេះ គឺកណ្ឌព្រះគម្ពីរនាងអេសធើរ។ សព្វថ្ងៃមានគ្រីស្ទបរិស័ទច្រើនណាស់ ដែលរស់នៅលើមាត់ជ្រោះ ដែលមានជីវអិលផ្អោះទៅខាងច្រកដែលដើរដាច់ឆ្ងាយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ជីវិតរបស់គេរស់នៅក្រៅព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់សម្រាប់ជីវិតគេ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់នៅតែដឹកនាំរាស្រ្តរបស់ទ្រង់ ដើម្បីអោយដើរត្រឡប់មករកបំណងព្រះហឫទ័យរបស់ទ្រង់វិញ។ ព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងគម្ពីរនាងអេសធើរ ជាឧទាហរណ៍ស្រាប់។

ឥឡូវយើងឈានចូលមកដល់ បេះដូងនៃព្រឹត្តិការណ៍ក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរហើយ។ ព្រឹត្តិការណ៍នេះ ចាប់ផ្តើមឡើងដោយមានការណែនាំអោយយើង

ស្គាល់សាសន៍យូដាម្នាក់ ឈ្មោះម៉ាដេកាយជាកូនគីសក្នុងពូជបេនយ៉ាមីន។ តើលោកម៉ាដេកាយ មកធ្វើអ្វីនៅក្នុងទីក្រុងនេះ? លោកម៉ាដេកាយជារាជវង្សរបស់សាសន៍អ៊ីស្រាអែល ពីព្រោះស្តេចសូលត្រូវជាកូនលោកគីសដែរ។ ស្តេចសូលគឺជាក្សត្រទីមួយរបស់សាសន៍អ៊ីស្រាអែល។

**គាត់ត្រូវដឹកនាំចេញពីទីក្រុងយេរូសាឡិម ជាមួយនឹងពួកឈ្លើយដែលបាននាំទៅ ក្នុងគ្រាដែលនេប៊ូក្នេសា ជាស្តេចបាប៊ីឡូនបានចាប់យេកូនាស ជាស្តេចយូដានាំយកទៅ (នាងអេសធើរ២:៦)។**

ព្រះជាម្ចាស់បើកផ្លូវអោយរាស្ត្ររបស់ទ្រង់ដែលជាប់ជាឈ្លើយសង្គ្រាម អាចត្រឡប់ទៅនគររបស់ខ្លួនវិញ ដូចហោរាអេសាយបានទាយទុកកន្លងមក។ ស្តេចស៊ីរុសបានចេញព្រះរាជក្រឹត្យអនុញ្ញាតអោយសាសន៍យូដា ត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។ អ្នកដែលព្រមត្រឡប់ទៅស្រុកវិញ គឺជាអ្នកដែលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ នៅក្នុងចំណោមសាសន៍យូដាមានមនុស្សតិចណាស់ ដែលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយព្រមត្រឡប់ទៅស្រុកកំណើត។ សាសន៍យូដាជាច្រើនលាននាក់ទៀត សម្រេចចិត្តតាំងទីលំនៅនៅក្នុងទឹកដីសាសន៍ដទៃ ជាទឹកដីដែលទទួលងារថាជាអ្នកជម្លៀស។ លុះគេស្នាក់នៅក្នុងទឹកដីសាសន៍ដទៃយូរទៅ សាសន៍ដទៃជាផ្ទះរបស់គេ ដូច្នេះ គេសម្រេចចិត្តមិនត្រឡប់ទៅស្រុកកំណើតវិញ។ បើគេខ្វះ

សេរីភាព មិនអាចត្រឡប់ទៅស្រុកវិញបាន នោះជារឿងធម្មតា។ ប៉ុន្តែ ឥឡូវព្រះជាម្ចាស់បានផ្តល់អោយគេមានសេរីភាពហើយ គេនៅតែមិនព្រមត្រឡប់ទៅស្រុកកំណើតវិញដែរ។ អ្នកទាំងនោះសុខចិត្តរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ លោកម៉ាដេកាយ ក៏ជាបុរសម្នាក់សម្រេចចិត្តរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ តាមពិតលោកម៉ាដេកាយត្រូវត្រឡប់ទៅរស់នៅស្រុកអ៊ីស្រាអែលវិញ។ មិនដូច្នោះទេ លោកម៉ាដេកាយសម្រេចចិត្តរស់នៅក្នុងទឹកដីជានគររបស់សាសន៍ដទៃ។ សូមសង្កេតមើលអោយច្បាស់ពីដំណើររនេះថា លោកម៉ាដេកាយបានរស់នៅក្នុងព្រះបរមរាជវាំង ដូច្នេះនាទីរបស់លោកគឺជាអ្នកនយោបាយមួយរូប។

ព្រះជាម្ចាស់អាចប្រើបុគ្គលជារាស្ត្ររបស់ព្រះអង្គ នៅក្នុងឆាកនយោបាយបានដែរ។ ព្រះអង្គប្រើយ៉ូសែបអោយបំពេញតួនាទីជាអ្នកនយោបាយ នៅក្នុងប្រទេសអេស៊ីព្ទ។ ក្នុងហេតុការណ៍នោះ ទ្រង់ចាត់លោកយ៉ូសែបអោយបំពេញបំណងព្រះហឫទ័យរបស់ទ្រង់។ នៅក្នុងរាជាណាចក្របាប៊ីឡូន ព្រះជាម្ចាស់តែងតាំងលោកដានីយ៉ែលអោយធ្វើជាអ្នកនយោបាយដែរ។ តួនាទីរបស់លោកដានីយ៉ែល ស្ថិតនៅក្នុងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដោយឡែកលោកម៉ាដេកាយ មិនមែនស្ថិតនៅក្នុងព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់ទេ។ លោកត្រូវធ្វើដំណើរត្រឡប់ទៅស្រុកវិញ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់ឧបត្ថម្ភដល់រាស្ត្រទ្រង់ ដើម្បីអោយសម្រេចតាមទិសដៅរបស់ព្រះអង្គ។ លោកអ្នកនឹងឃើញហេតុការណ៍នេះ កើតមានឡើងនៅក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរ។

ការឧបត្ថម្ភរបស់ព្រះជាម្ចាស់មានន័យថា ព្រះអង្គជួយទំនុកបំរុងដល់មនុស្សលោក ដោយតម្រង់ទិសពីក្រោយខ្នង។ លោកម៉ាដេកាយជាអ្នកដឹកនាំជីវិតរបស់លោក ប៉ុន្តែ ព្រះជាម្ចាស់ជាអ្នកកាច់ចង្កូតនាវាជីវិតលោកម៉ាដេកាយពីក្រោយខ្នង។ លោកម៉ាដេកាយក៏ដូចជាសាសន៍យូដាទាំងមូល ដែលរស់នៅសម័យនាងអេសធើរដែរ គេមិនបានស្វែងរកព្រះជាម្ចាស់ ជាជំនួយរបស់គេទេ។ នៅពេលដែលគេមានទុក្ខលំបាក គេមិនបានបែរទៅរកព្រះអង្គ។ នៅក្នុងគម្ពីរនាងអេសធើរទាំងមូល យើងមិនឃើញមាននិយាយពីនាមរបស់ព្រះជាម្ចាស់ ឬពីសេចក្តីអធិស្ឋានឡើយ។ ឯមូលហេតុ គឺសាសន៍យូដាទាំងនោះស្ថិតនៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូច្នេះ គេមិនរាប់ព្រះជាម្ចាស់ថា ជាអង្គមានលក្ខណៈសំខាន់នៅក្នុងជីវិតរបស់គេ។

លោកម៉ាដេកាយនិងនាងអេសធើរ មានដំណើរជីវិតមិនល្អជាប្រក្រតីទេ ទោះបីអ្នកទាំងពីរជាអ្នកមានមុខមានមាត់នៅក្នុងសង្គមក៏ដោយ។ លោកម៉ាដេកាយត្រូវគេជម្លៀសអោយមកនៅប្រទេសបាប៊ីឡូនតាំងពីវ័យក្មេងម្ល៉េះ។ លោកបានធ្វើដំណើរមកដល់ទឹកដីដែលគេជម្លៀសក្នុងលើកទីពីរ។ គ្រានោះ ត្រូវជារាជ្យរបស់ក្សត្រយេហូយ៉ាគីន។ ការជម្លៀសត្រូវធ្វើឡើងជាបីលើក។ លើកទីមួយគេបានចាប់ពួកស្តេច ពួកមន្ត្រី និងពួកត្រកូលអភិជនទាំងអស់នាំចេញមក។ លោកដានីយ៉ែល ស្ថិតនៅក្នុងចំណោមពួកជនទាំងនោះ។ ការជម្លៀសលើកទីពីរ ជាការនាំពួកអ្នកមានធម្មតា និងពួកត្រកូលថ្នាក់កណ្តាល។ លោកម៉ាដេកាយស្ថិតនៅក្នុងជំពូកជនប្រភេទនេះ។

ការជម្លៀសលើកទីបី ធ្វើឡើងនៅពេលដែលគេបំផ្លាញចោលទីក្រុង

យេរូសាឡិមទាំងស្រុងតែម្តង។ នៅពេលនោះគេជម្លៀសមនុស្សទាំងអស់ លើកលែងតែជនក្រីក្រជាងគេបំផុត ដែលគេទុកអោយនៅរក្សាទីក្រុង។ លោកម៉ាដេកាយមានប្អូនស្រីជីដូនមួយម្នាក់ ត្រូវជាកូនឪពុកមារបស់លោក ដែលត្រូវស្តេចនេប៊ូក្នេសាសម្លាប់ពេលបំផ្លាញទីក្រុងយេរូសាឡិម។ នៅពេលនោះមានមនុស្សជាច្រើនម៉ឺននាក់ ត្រូវគេប្រហារជីវិត។

> **គាត់បានចិញ្ចឹមនាងហាដាសា គឺអេសធើរ ជាកូនរបស់មាគាត់ ដ្បិតនាងគ្មានឪពុកម្តាយ នាងមានរូបឆោមឆាយ ហើយមុខស្រស់ល្អ កាលឪពុកម្តាយនាងស្លាប់ទៅហើយ នោះម៉ាដេកាយបានយកនាងមកចិញ្ចឹមទុកជាកូនខ្លួន (នាងអេសធើរ២:៧)។**

នាងអេសធើរមានឈ្មោះជាភាសាហេព្រើរថាហាដាសា ដែលមានន័យថា "ដូងតារា"។ បើតាមព្រះគម្ពីរនាងអេសធើរមានសម្ផស្សស្រស់ល្អដូចផ្កាយព្រឹក។ លោកម៉ាដេកាយបានយកនាងអេសធើរមកចិញ្ចឹមធ្វើជាកូនបង្កើតរបស់លោក។ នាងអេសធើរមានរូបសម្បត្តិល្អជាងគេបង្អស់ គឺរូបឆោមលោមពណ៌របស់នាងស្រស់ល្អណាស់។ នៅពេលដែលស្តេចអ័ហាស៊ូរុសចេញបញ្ជាអោយរើសស្រីក្រមុំធ្វើជាអគ្គមហេសី លោកម៉ាដេកាយបានចុះឈ្មោះនាងអេសធើរ បញ្ចូលទៅក្នុងបញ្ជីជ្រើសរើសបវរកញ្ញាដែរ។ មុខនាទីរបស់លោកម៉ាដេកាយ គឺជាអ្នកមើលការខុសត្រូវលើនារីទាំងអស់ ដែលត្រូវ

យកមកធ្វើជាអនាគតអគ្គមហេសីរបស់ស្តេច។ បើតាមខ្ញុំយល់ លោកម៉ាដេកាយមាន នាងអេសធើរនៅក្នុងចិត្តរួចស្រេចហើយ។ លោកតែងតែប្រៀបធៀបនារីឯទៀតជាមួយ នឹងសម្រស់របស់កូនស្រីចិញ្ចឹមរបស់លោក។

> **៨ ដូច្នេះ កាលគេបានប្រកាសប្រាប់ព្រះរាជឱង្ការ នឹងច្បាប់របស់
> ស្តេច ហើយបានប្រមូលស្រីក្រមុំជាច្រើនមកឯស៊ូសាន ជាក្រុង
> ហ្លួងប្រគល់ក្រោមអំណាចហេកាយ នោះគេក៏នាំយកអេសធើរ
> ទៅក្នុងដំណាក់ស្តេច ប្រគល់ក្រោមអំណាចហេកាយ ជាអ្នករក្សា
> ពួកស្រីៗដែរ ៩ នាងជាទីពេញចិត្តដល់គាត់ណាស់ គាត់ក៏សំដែង
> សេចក្តីសប្បុរសដល់នាង ក៏ប្រញាប់នឹងចែកគ្រឿង សំរាប់ឱ្យ
> នាងជំរះខ្លួន នឹងប្រដាប់តែងកាយ ដែលជាចំណែករបស់នាង
> ព្រមទាំងយកស្ត្រីក្រមុំ៧នាក់ ពីព្រះរាជដំណាក់មកឱ្យបំរើនាង
> ហើយគាត់ក៏ផ្លាស់នាង នឹងស្រីបំរើទាំងនោះ ឱ្យទៅនៅក្នុងបន្ទប់
> ល្អបំផុត ក្នុងមន្ទីរពួកស្រីៗ (នាងអេសធើរ២:៨-៩)។**

នៅក្នុងស្ថានភាពខាងលើ យើងឃើញព្រះជាម្ចាស់កំពុងផ្តល់ការឧបត្ថម្ភគាំទ្រ ចំពោះរាស្ត្ររបស់ទ្រង់។ លោកម៉ាដេកាយទទួលយកនាងអេសធើរ ត្រូវជាប្អូនជីដូនមួយ របស់លោក ដែលលោករាប់ថាជាកូន អោយចូលរួមនៅក្នុងពិធីប្រលងប្រជែងជ្រើស

រើសអគ្គមហេសី។ នៅក្នុងចំណុចមួយនេះ ខ្ញុំសុំសម្តែងការមិនគោរពចំពោះលោកម៉ាដេកាយនូវកិរិយាដែលលោកកំពុងតែប្រព្រឹត្ត។ ប៉ុន្តែ មុននឹងយើងបញ្ចប់រឿងនាងអេសធើរ ខ្ញុំត្រូវប្តូរជំហររបស់ខ្ញុំ ពោលគឺខ្ញុំត្រូវបង្វិលេបពាក្យរបស់ខ្ញុំ ហើយលើកលោកម៉ាដេកាយថា ជាមនុស្សល្អវិញ។ ប៉ុន្តែ ក្នុងចំណុចដែលខ្ញុំកំពុងតែនិយាយនេះ ខ្ញុំមិនគោរពដល់លោកម៉ាដេកាយទេ។ តើយើងគោរពលោកម៉ាដេកាយដូចម្តេចកើត ពីព្រោះទីមួយ លោកមិនស្តាប់បង្គាប់ដល់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បង្គាប់រួចហើយថា មិនត្រូវអោយរាស្ត្ររបស់ទ្រង់រៀបការជាមួយនឹងអ្នកមិនជឿ។ លោកដឹងថាស្តេចស៊ូរុសជាអ្នកមិនជឿ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ លោកសុខចិត្តបំពានក្រឹត្យវិន័យរបស់ព្រះដោយយកកូនរបស់លោកអោយចូលទៅប្រកួតប្រជែង ដើម្បីធ្វើជាអគ្គមហេសីរបស់ស្តេច។ ក្នុងការជ្រើសរើសយកនារីម្នាក់មកធ្វើជាអគ្គមហេសីរបស់ស្តេច យុវនារីព្រហ្មចារីគ្រប់រូប ចាំបាច់ត្រូវរួមដំណេកជាមួយនឹងស្តេចបានមួយយប់សិន។ បើស្តេចពេញចិត្ត ស្តេចលើកឡើងធ្វើជាអគ្គមហេសី។ ឧទាហរណ៍ថានាងអេសធើរមិនជាប់ជាអគ្គមហេសី តើវាសនារបស់នាងនឹងទៅជាយ៉ាងណា? នាងអេសធើរនឹងត្រូវទៅធ្វើជាភីលៀងរបស់ស្តេច។ ក្នុងនាមជាភីលៀងរបស់ស្តេច ជីវិតរបស់នាងមានការជូរចត់យ៉ាងខ្លាំង ពីព្រោះនាងគ្មានសិទ្ធិរកប្តី ធ្វើជាអនាគតរបស់នាងទៀតទេ។ នាងត្រូវរស់ក្រោមសេចក្តីមេត្តាករុណារបស់ស្តេច។ បើស្តេចគ្រាន់តែហៅនាងទៅរួមដំណេកម្តងម្យាម នោះរាប់ថាជាគុណរបស់ស្តេច។ ដូច្នេះ ម៉ាដេកាយបានធ្វើការអាក្រក់នេះចំពោះកូនរបស់លោក ក៏ដូចចំពោះសាសន៍យូដាដែរ។ លោកម៉ាដេកាយធ្វើការប្រថុយ

ប្រថានរឿងនេះខ្លាំងណាស់។ ខ្ញុំមិនចូលចិត្តគាត់ទេ។

ប៉ុន្តែ យើងឃើញព្រះហស្តរបស់ព្រះ កំពុងគ្រប់គ្រងនៅលើស្ថានភាពមួយនេះ។ គេនាំនាងអេសធើរចូលទៅជំណាក់ស្តេច។ នាងអេសធើរជាទីពេញចិត្តរបស់លោកម៉ាដេកាយដែលត្រូវជាអ្នកគ្រប់គ្រងលើនារី ដែលត្រូវចូលទៅជ្រើសរើសធ្វើជាអគ្គមហេសីរបស់ស្តេច។ លោកម៉ាដេកាយផ្តល់នូវគ្រប់អ្វីៗទាំងអស់ ដែលនាងអេសធើរត្រូវការដើម្បីធ្វើអោយរូបសម្ផស្សរបស់នាងរឹតតែល្អឡើង។

**ឯអេសធើរ នាងមិនបានប្រាប់ឱ្យអ្នកណាដឹងថា ត្រកូល នឹងជំនួរវង្សរបស់នាងជាសាសន៍អ្វីទេ ដ្បិតម៉ាដេកាយបានហាមមិនឱ្យនាងប្រាប់ឱ្យគេដឹងឡើយ (នាងអេសធើរ២:១០)។**

ហេតុអ្វីបានជាលោកម៉ាដេកាយ មិនចង់អោយនាងអេសធើរប្រាប់គេថា នាងមានជាតិសាសន៍ជាអ្វី? នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោក ទោះបីជាជាតិសាសន៍ណាក៏ដោយ គេតែងរាប់សាសន៍អ៊ីស្រាអែលថាជាសត្រូវ។ នៅសម័យដើម ពិសេសក្នុងជំនាន់ក្សត្រនេប៊ូក្នេសាឡើងទៅវាយកំទេចទីក្រុងយេរូសាឡិម ស្តេចអង្គនេះស្អប់សាសន៍យូដាខ្លាំងណាស់។ ស្តេចអង្គនេះ បានចាប់សាសន៍យូដាធ្វើជាឈ្លើយសឹកហើយជម្លៀសអោយមកនៅប្រទេសបាប៊ីឡូន។ ឥឡូវនេះ ស្តេចនេប៊ូក្នេសាបានចូលទីវង្គតទៅ តែគំនិតប្រឆាំងពីសំណាក់ពូជពង្សស្តេចអង្គនេះ ឥតមានប្តូរផ្លាស់អ្វីទេ។

លោកម៉ាដេកាយជ្រាបពីដំណើរនោះ បានជាលោកហាមប្រាមដល់នាងអេសធើរ មិនអោយប្រាប់គេពីពូជពង្សរបស់នាង។ ការលាក់អត្តសញ្ញាណថាខ្លួនជាសាសន៍យូដា គឺជាការលាក់សាសនារបស់ខ្លួនដែរ។ សាសនាគឺជាអត្តសញ្ញាណបញ្ជាក់ពីមនុស្សណាម្នាក់ថា ខ្លួនជាជនជាតិណាមួយអោយបានពិតប្រាកដ។ នៅក្នុងករណីសាសន៍យូដា សាសនារបស់គេគឺថ្វាយបង្គំដល់ព្រះជាម្ចាស់។ នៅក្នុងខណៈដែលលោកម៉ាដេកាយ និងនាងអេសធើរបដិសេធមិនទទួលស្គាល់ជាតិសាសន៍របស់ខ្លួន អ្នកទាំងពីរបដិសេធមិនទទួលស្គាល់សាសនារបស់ខ្លួនដែរ។ អ្នកទាំងពីររស់នៅក្នុងចំណោមសាសន៍យូដារាប់លានអ្នកទៀត ដែលស្ម័គ្រចិត្តរស់ក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ទាក់ទងនឹងសេចក្តីពិតនេះ បុរសនិងស្ត្រីណាដែលរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គេមិនលើកតម្កើងជំនឿរបស់គេលើព្រះអម្ចាស់យេស៊ូវថា មានលក្ខណៈសំខាន់ទៀតទេ។

**ឯម៉ាដេកាយ គាត់ក៏តែងដើរទៅមកនៅមុខទីធ្លាមន្ទីរពួកស្រីៗជារាល់ថ្ងៃ ដើម្បីឱ្យដឹងជាអេសធើរជាយ៉ាងណា ហើយនឹងបានទៅជាអ្វី (នាងអេសធើរ២:១១)។**

ក្នុងខណៈដែលលោកអ្នក ស្ថិតនៅក្នុងរង្វង់ព្រះហឫទ័យបំណងរបស់

ព្រះជាម្ចាស់ លោកអ្នកអាចសម្រាកព្រលឹងរបស់លោកអ្នកលើព្រះជាម្ចាស់ ថាទ្រង់អាចប្រើគ្រប់ការណ៍ទាំងអស់ សម្រាប់ជាសិរីល្អដល់យើងក៏ដូចជាតម្កើងព្រះនាមរបស់ទ្រង់ដែរ។ លោកម៉ាដេកាយមិនមានសេចក្តីសម្រាកណានៅក្នុងចិត្តទេ ពីព្រោះលោកកំពុងរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ លោកដើរចុះដើរឡើង ពីមុខទៅក្រោយ ពីស្តាំ ទៅឆ្វេង មិនឈប់មិនឈរ។ ពេលខ្លះលោកខាំក្រចក គិតវែងឆ្ងាយថា មិនដឹងជារឿងរបស់នាងអេសធើរ និងត្រូវធ្លាក់ទៅជាយ៉ាងណា។ ម្យ៉ាងទៀតលោកព្រួយបារម្ភក្រែងលោនាងអេសធើរមិនបានជាប់ជាអគ្គមហេសី នោះលោកបានធ្វើអោយអនាគតរបស់នាងជួបនឹងភាពខ្មៅងងឹតជាយថាហេតុ។ ដោយសារលោកខ្លាចរឿងនេះហើយ បានជាលោកព្រួយបារម្ភ លោកដេកមិនលក់ បក់មិនល្ហើយ លោកពិបាកនៅក្នុងចិត្ត ហើយពោះរបស់លោកផឹតចុះផឹតឡើង ដោយការភ័យព្រួយយ៉ាងខ្លាំងនោះ។ ពេលលោកអ្នកដើរក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ចិត្តលោកអ្នកគ្មានការសម្រាកទេ។ លោកអ្នកចេះតែភ័យព្រួយខ្លាចលោអ្នកនេះធ្វើអ្វីដល់លោកអ្នក ឬរឿងនោះនឹងទៅជាយ៉ាងនេះ ឬអ្នកនឹងទទួលលទ្ធផលបែបណាមួយ។ មែនហើយ ការស្ថិតនៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជាការវេទនាដល់ជីវិតខ្លាំងណាស់។ លោកម៉ាដេកាយមិនបានប្រគល់រឿងដែលលោកបានធ្វើទៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់។ តាមពិតលោកម៉ាដេកាយមិនដឹងថា ព្រះជាម្ចាស់មានផែនការនៅក្នុងរឿងនេះថែមទៀតផង។ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់កំពុងតែគ្រប់គ្រងស្ថានភាពនេះ។

ខ្ញុំសូមរំឭកដល់លោកអ្នកបងប្អូនម្ដងទៀត ពីខ្លឹមសារនៃពាក្យដែលថា ព្រះជាម្ចាស់ឧបត្ថម្ភគាំទ្រ។ ការឧបត្ថម្ភគាំទ្ររបស់ព្រះជាម្ចាស់ គឺជាការដឹកនាំដែលព្រះជាម្ចាស់ផ្ដល់ទៅមនុស្សម្នាក់ ដោយមនុស្សនោះមិនបានទាំងដឹងខ្លួនផង។ យើងនឹងឃើញរឿងនេះយ៉ាងជាក់ស្ដែង នៅក្នុងចំណុចដែលយើងកំពុងតែសិក្សានេះ។ រឿងដែលនាងអេសធើរបានជាប់ធ្វើជាអគ្គមហេសីរបស់ស្ដេច មិនមែនជារឿងចៃដន្យឡើយ។ ការស្ថិតនៅក្នុងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មិនដែលមានគ្រោះថ្នាក់ឡើយ។

សូមលោកអ្នកកត់ចំណាំពីគ្រឿងសម្អាង ដែលប្រើនៅក្នុងពេលដែលគេតុបតែងកូនក្រមុំ មុននឹងយកទៅថ្វាយស្ដេច។

**រីឯតាមទំនៀមពួកស្រីៗ នោះពេលដែលជំរះខ្លួន ត្រូវអស់រវាង ១២ខែ គឺ៦ខែដោយប្រេងល្វីងទេស ហើយ៦ខែដោយគ្រឿងក្រអូបផ្សេងៗ ព្រមទាំងគ្រឿងអ្វីៗដែលសំរាប់ឲ្យពួកស្រីៗបានស្អាតបរិសុទ្ធផង ដូច្នេះ ក្រោយដែលគេបានធ្វើដល់នាងទាំងនោះតាមទំនៀម ហើយពេលដែលនាងណាត្រូវចូលទៅឯស្តេចអ័ហាស៊ូរុសបានមកដល់ (នាងអេសធើរ២:១២)។**

គេត្រូវប្រើពេលវេលាយ៉ាងយូរដើម្បីអប់រំនារីគ្រប់រូបៗ មុននឹងយកទៅថ្វាយ

ស្តេច។ ទាក់ទងនឹងហេតុការណ៍នេះ បើភរិយារបស់លោកអ្នកចំណាយពេលពីរឬបីម៉ោងនៅក្នុងកន្លែងធ្វើសក់ ធ្វើក្រចក សូមកុំអោយខឹងជាមួយនាងអោយសោះ។ ពួកនារីដែលគេត្រូវយកទៅថ្វាយស្តេច ត្រូវអោយនាងតុបតែងខ្លួនអស់រយៈពេលមួយឆ្នាំ។ ប្រាំមួយខែដំបូងគេអោយនាងសម្រកខ្លាញ់សម្រកទម្ងន់ ដើម្បីអោយត្រូវប៉ាន់នឹងសម្រស់ដែលក្សត្រចង់បាន។ លុះប្រាំមួយខែបន្ទាប់មកទៀតគេប្រើទឹកអប់ ដើម្បីអប់នាងអោយមានក្លិនក្រអូបរាល់ថ្ងៃ។ បើតាមខ្ញុំយល់នៅក្នុងឆ្នាំដែលគេរើសបវរកញ្ញានេះ ទឹកអប់នៅតាមផ្សារលក់ដាច់ខ្លាំងណាស់។ លោកអ្នកឃើញហើយនៅក្នុងចំណុចនេះ គឺសាសន៍ដទៃ គេយកចិត្តទុកដាក់នឹងសម្រស់ខាងក្រៅ។ ប្រទេសអ្នកមានសព្វថ្ងៃ ពិសេសសហរដ្ឋអាមេរិក ច្រើនតែភ្លេចខ្លួនថា អំណាចនិងទ្រព្យសម្បត្តិដែលគេមាននៅលើពិភពលោក គឺដោយសារព្រះជាម្ចាស់បានលើកគេអោយខ្ពស់ឡើង។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ពលរដ្ឋសហរដ្ឋអាមេរិកភាគច្រើន នាំគ្នាលង់ខ្លួនទៅក្នុងការកែសម្ផស្ស។ លោកអ្នកប្រហែលជាជ្រាបហើយថា គ្រឿងសម្អាងដែលល្អៗច្រើនមកពីប្រទេសអ្នកមានដូចជាប្រទេសអាមេរិក ប្រទេសបារាំង និងប្រទេសជប៉ុនជាដើម។ ប៉ុន្តែ ទោះជាប្រើគ្រឿងសម្អាងយ៉ាងណាក៏ដោយ នារីខ្លះកែមិនឡើងតែម្តង។ ពួកនារីដែលគេបំរុងយកទៅថ្វាយស្តេច ត្រូវប្រើពេលមួយឆ្នាំ ដើម្បីតុបតែងខ្លួន។

បើតាមយើងសង្កេតពីរបៀបតុបតែងខ្លួនខាងលើ ពួកស្រីៗមិនដែលប្តូរផ្លាស់កិរិយារបស់គេទេ តាំងពីមនុស្សលោកមាននៅលើផែនដីនេះ។ មុននឹងគេចូលទៅប្រលងបវរកញ្ញា គេតុបតែងខ្លួនយ៉ាងខ្លាំង។ សព្វថ្ងៃ យើងឃើញមានគ្រឿងសម្អាង

ច្រើនណាស់ ដែលមានលក់នៅតាមទីផ្សារ។ ស្ត្រីៗដែលមានគ្រួសារហើយ ក៏ដូចជានារី គេនាំគ្នាដេញតាមគ្រឿងសម្អាងនោះឥតឈប់ឈរឡើយ។ ទាក់ទងនឹងហេតុការណ៍នេះ មានអ្នកខ្លះសួរថា តើគ្រីស្ទបរិស័ទអាចតុបតែងខ្លួនបានខ្លះដែរឬទេ? មានគ្រីស្ទបរិស័ទខ្លះដែលប្រកាន់ជំនឿជ្រុលនិយម គេនិយាយថា គ្រីស្ទបរិស័ទមិនត្រូវតុបតែងខ្លួនអ្វីទេ ពីព្រោះគម្ពីរហាមប្រាមមិនអោយតុបតែងខ្លួនខាងក្រៅ គឺត្រូវតុបតែងខាងក្នុងវិញ។ មែនហើយ ព្រះគម្ពីរសម្តែងយ៉ាងដូច្នោះមែន។ ប៉ុន្តែ មិនមែនមានន័យថា យើងជាគ្រីស្ទបរិស័ទចេះតែធ្វើដំណើរទៅណា គោកក្រៀមដូចត្រីក្រាញ់ប្រឡាក់ភក់អាំងកម្តៅថ្ងៃនោះទេ។ ខ្ញុំប្រកាន់ជំហរថា បើនារីៗប្រើគ្រឿងសម្អាងខ្លះៗ អាចធ្វើអោយនាងមើលទៅគួរពេញភ្នែកដែរ។ ដូច្នេះ បើគ្រីស្ទបរិស័ទចង់ប្រើគ្រឿងសម្អាងតិចតួចសូមប្រើចុះ កុំអោយតុបតែងខ្លួនដូចនាងភីមរាំថៃយ៉ាំពេលដើរវៃលុយ។

ក្នុងករណីនាងអេសធើរ ព្រះជាម្ចាស់បណ្តោយអោយហេតុការណ៍នេះកើតឡើង ពីព្រោះរឿងនោះស្ថិតនៅក្នុងកម្មវិធី នៃការឧបត្ថម្ភគាំទ្ររបស់ទ្រង់។ ព្រះអង្គអនុញ្ញាតអោយនាងចូលទៅ ដើម្បីទទួលការជ្រើសរើសធ្វើជាអគ្គមហេសីរបស់ស្តេច។ ព្រះអង្គតែងតាំងអោយលោកម៉ាដេកាយគ្រប់គ្រងរឿងនេះទាំងស្រុង។ លោម៉ាដេកាយ ដែលជាអ្នករក្សានារីព្រហ្មចារីទាំងនោះគិតស្រេចរួចហើយថា នាងអេសធើរពិតជាឈ្នះក្នុងការប្រលងនេះ។ ក្នុងចំណុចដែលយើងកំពុងសិក្សានេះ លោកម៉ាដេកាយហាក់ដូចជាដើរចំផ្លូវដែលព្រះជាម្ចាស់កំពុងមានគម្រោងការ។ ដំណើរនោះមិនមែនជាគ្រោះថ្នាក់ទេ។ សេចក្តីឧបត្ថម្ភគាំទ្ររបស់ព្រះជាម្ចាស់កំពុងគ្រប់គ្រងជីវិតរបស់

នាងអេសធើរ។

**[១៣]នោះនាងបានចូលទៅឯស្តេចបែបយ៉ាងនេះឯង គឺអ្វីៗ ដែលនាងប្រាថ្នាចង់បាន នោះក៏បានបើកឱ្យនាង ដើម្បីនឹងយកពីមន្ទីរពួកស្រីៗ ទៅឯដំណាក់ស្តេច [១៤]នៅពេលល្ងាចនាងបានចេញទៅ ហើយដល់ព្រឹកឡើងនាងវិលមកវិញ ចូលក្នុងមន្ទីរទី២ របស់ពួកស្រីៗ នៅក្រោមអំណាចស្អាសកាស ជាភ្នាក់ងាររបស់ស្តេចដែលរក្សាពួកស្រីអ្នកម្នាង នាងនោះលែងបានចូលទៅចំពោះស្តេចទៀតហើយ លើកតែស្តេចទ្រង់សព្វព្រះទ័យនឹងនាង ហើយហៅតាមឈ្មោះវិញ (នាងអេសធើរ២:១៣-១៤)។**

បន្ទាប់ពីរៀបចំខ្លួនអស់រយៈពេលមួយឆ្នាំមក ពេលវេលាដែលត្រូវយកនារីព្រហ្មចារីចូលទៅថ្វាយស្តេចម្តងមួយបានមកដល់។ នារីព្រហ្មចារីណាក៏ដោយ មុននឹងចូលទៅអោយស្តេចផ្ទំ នាងអាចសុំអ្វីៗបានទាំងអស់ ទាំងពីខោអាវ ទាំងគ្រឿងអលង្ការជាដើម។ នាងត្រូវចូលទៅពេលល្ងាច លុះព្រលឹមឡើងនាងត្រូវចេញពីដំណាក់ស្តេចមកវិញ។ នារីណាដែលស្តេចមិនពេញចិត្ត ស្តេចមិនហៅនារីនោះមកវិញទៀតទេ។ មិនយូរប៉ុន្មានវេនរបស់នាងអេសធើរក៏បានមកដល់។ ដូចខ្ញុំបានជម្រាបរួចមកហើយថា នាងអេសធើរកំពុងប្រថុយជីវិតយ៉ាងខ្លាំងក្លា។ បើនាងមិនជាប់ជាអគ្គមហេសី នាងនឹង

ក្លាយត្រឡប់ទៅជាភីលៀងមួយរូបរបស់ស្តេចចក្រភពពើស៊ី។ មុខនាទីនេះ ជាមុខនាទីវេទនាជាទីបំផុត ពិសេសសម្រាប់នារីម្នាក់ជាសាសន៍យូដា។ ដោយសារមូលហេតុនេះហើយ បានជាលោកម៉ាដេកាយដេកមិនលក់ បក់មិនល្ហើយ ជូនខាំក្រចកដៃ ជូនឱនខាំក្រចកជើង ជូនខាំបបូរមាត់ខ្លួនក៏មានដែរ។ លោកដឹងថា លោកកំពុងដើរក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ម្យ៉ាងទៀតលោកដឹងថា ជាកាប្រថុយប្រថានណាស់ ដែលលោកបានប្រគល់កូនស្រីរបស់ខ្លួន ដែលមានរូបសម្ផស្សដូចផ្កាយព្រឹកទៅអោយប្រលងប្រជែងនាទីជាអគ្គមហេសី។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់គ្រប់គ្រងស្ថានភាពនោះទាំងស្រុង។

> **ឯអេសធើរ កូនអ័ប៊ីហែល ជាមារបស់ម៉ាដេកាយ ដែលបានយកមកចិញ្ចឹមទុកជាកូនខ្លួន កាលដល់ពេលដែលនាងត្រូវចូលទៅឯស្តេច នោះនាងមិនបានសូមអ្វីក្រៅពីរបស់ដែលហេកាយ ជាក្រមរាំងរបស់ស្តេច ជាអ្នករក្សាពួកស្រីៗ បានឱ្យនោះទេ ហើយអស់អ្នកណាដែលឃើញនាង ក៏ពេញចិត្តនឹងនាង (នាងអេសធើរ២:១៥)។**

នៅពេលដែលនាងអេសធើរត្រូវចូលទៅឯស្តេច នាងសម្រេចចិត្តថា នាងមិនធ្វើខ្លួនអ្វីទាំងអស់ គឺព្រះជាម្ចាស់បង្កើតនាងមករបៀបណា នាងចូលទៅស្តេចរបៀប

នោះ។ នៅយប់នោះអ្នកទទួលខុសត្រូវគ្រឿងសម្អាងមិនរវល់អ្វីឡើយ។ នាងមានរូបឆោមលោមពណ៌ស្អាតបែបធម្មជាតិ។ គេគ្រប់គ្នាមើលមកនាងគិតក្នុងចិត្តថា នាងប្រាកដជាជាប់ហើយ។ នាងអេសធើរមានប្រៀបលើនារីព្រហ្មចារីដទៃៗទៀត។ តើលោកអ្នកមិនបានឃើញថា ព្រះហស្តរបស់ព្រះជាម្ចាស់កំពុងសម្រេចការនេះទេឬ? ប្រាកដណាស់ ព្រះហស្តរបស់ព្រះជាម្ចាស់កំពុងស្ថិតនៅលើនាង ដ្បិតនាងស្ថិតនៅក្នុងកម្មវិធីការឧបត្ថម្ភគាំទ្ររបស់ព្រះអង្គ។ ចាប់ពីថ្ងៃស្អែកទៅ នាងនឹងក្លាយត្រឡប់ទៅជាអគ្គមហេសីរបស់ព្រះមហាក្សត្រ។ នាងគង់នៅជាមួយបល្ល័ង្កទន្ទឹមនឹងស្ដេច។ នាងជាបុគ្គលទីពីរ គ្រប់គ្រងចក្រភពពើស៊ីទាំងមូល ដែលមាននគរ១២៧ជាចំណុះរបស់ស្ដេចស៊ូរុស។ បើនាងមិនបានឡើងមកបំពេញតួនាទីរបស់នាងជាអគ្គមហេសីទេ ម្ល៉េះសាសន៍អីស្រាអែល ប្រហែលជាត្រូវគេសម្លាប់ផ្ដាច់ពូជនៅក្នុងគ្រានោះ បាត់ពីប្រវត្តិសាស្ត្ររបស់មនុស្សលោកទៅហើយ។ បើហេតុការណ៍នោះកើតមែន ព្រះបន្ទូលសន្យាទាំងអម្បាលមាណរបស់ព្រះជាម្ចាស់ពិតជាអសាឥតការ។ ព្រះជាម្ចាស់មិនដែលបណ្ដោយអោយព្រះបន្ទូលរបស់ព្រះអង្គទៅជាអសាឥតការជាដាច់ខាត។ កាលណាព្រះមានបន្ទូលហើយ ផលផ្លែកើតមានឡើងជាយថាហេតុ។

យើងស្លេះការសិក្សាគម្ពីរនាងអេសធើរត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្ដម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"